# ជំនឿរាំត្រុដិក្នុងរដូវចូលឆ្នាំថ្មី

"ត្រុដិ" ជាពាក្យសំស្ក្រឹតដែលក្លាយមកពីពាក្យ "ត្រុស្តិ" មានន័យថា "ដំណើរកាត់, ការផ្តាច់"។[1] សង្គមខ្មែរចាត់ទុកត្រុដិ គឺជាល្បែងរបាំដែលអ្នកស្រុកតែងលេងក្នុងរដូវចូលឆ្នាំ ពោលគឺក្នុងន័យផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី។[2] បើតាមចំណាំ អ្នករាំត្រុដិ គឺជាក្រុមមនុស្សស្រីប្រុសតែងខ្លួនជា ព្រាន ព្រាយ យក្ស ទន្សោង និងប្រើសជាដើម (រូបលេខ១) ហើយអ្នកស្រាវជ្រាវយល់ថារបាំនេះមានដើមកំណើតក្នុងខេត្តភាគខាងជើង។ បច្ចុប្បន្នរបាំត្រុដិហាក់ក្លាយជាទម្រង់សិល្បៈទស្សនីយភាព ដែលគេស្គាល់ទូទៅថាជារបាំសម្រាប់សម្តែងបណ្តោញឧបទ្រព្យចង្រៃ និងរៃអង្គាសប្រាក់យកមកកសាង និងជួសជុលសមិទ្ធិក្នុងសហគមន៍ ជាពិសេសនៅតាមវត្តអារាម។ បច្ចុប្បន្ន គេសង្កេតឃើញនៅតាមបណ្តាក្រសួង មន្ទីរ និងក្រុមហ៊ុននានា តែងរៀបចំទទួលក្រុមរបាំត្រុដិមកសម្តែងក្នុងរដូវចូលឆ្នាំ។



រូបលេខ១ ក្រុមសិល្បៈរបាំត្រុដិ

---

[1] ក្រុមជំនុំវចនានុក្រមខ្មែរ ១៩៦៧: ៣៦៩ និង ៣៧៦, អាន រស្មី និង អាំង ជូលាន ២០២២: ២៧-៤០

[2] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ២០១៧:៥៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើផ្អែកតាមឯកសារប្រពៃណីខ្មែរ ប្រមូលចងក្រងដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរក្នុងរវាងពាក់កណ្ដាលសតវត្សរ៍ទី២០រៀបរាប់ថា "ត្រុដិជាល្បែងលេងក្នុងរដូវចូលឆ្នាំច្រើនមានតែក្នុងខេត្តសៀមរាប(រូបលេខ២-៣) ហើយមានចាស់ស្រុកម្នាក់ជាមេដឹកនាំកូនត្រុដិឱ្យលេង។ ជិតដល់រដូវចូលឆ្នាំ ចាស់ស្រុកនោះដាស់តឿនកូនស្រុកឱ្យធ្វើកញ្ញា ធ្វើមុខយក្ស ធ្វើប្រើស ធ្វើកាំភ្លើង ធ្វើដងសន្ទូច ធ្វើក្រចកម្រាមដៃ រកទិញឬធ្វើស្គរ ប៉ី (វង់ខ្លះមានទ្រផង) ហើយត្រូវមានអ្នកច្រៀងដែលមានសំឡេងពីរោះ មានទាំងអ្នកស្ពាយសំពាយផង ព្រោះល្បែងនេះលេងសូមមាសប្រាក់ សំពត់សៅអាវស្បៃ អំបោះ...បានរបស់ទាំងនោះមកឱ្យពួកអ្នកសំពាយ ស្ពាយតាមរហូតអស់រដូវចូលឆ្នាំ ទើបព្រមគ្នាយកទៅប្រគេនលោកសង្ឃ ហើយសូមសំណែនសំណល់មកចែកគ្នាគិតជាថ្លៃនឿយហត់។ ឯគ្រឿងប្រដាប់លេង ក៏រួបរួមគ្នាទុកក្នុងវត្ត ឬយកទៅទុកឯផ្ទះតាមម្ចាស់របស់រៀងៗខ្លួនក៏មាន ដល់ពេលចូលឆ្នាំថ្មី ក៏យករបស់ទាំងនោះមកលេងទៀត។ បើមានរបស់ឯណាបាក់បែក ក៏ជួសជុលឬធ្វើឡើងជាថ្មី លេងទៅតាមលំអានដើម។ វង់ខ្លះលេងរហូតពីខែចេត្រ ដល់ពិសាខក៏បមាន"។[៣]



រូបលេខ២ ត្រុដិរបស់អ្នកស្រុកសៀមរាប ក្នុងសម័យអាណាព្យាបាលបារាំង

(ប្រភព៖ EFEO)



រូបលេខ៣ ត្រុដិអ្នកស្រុកសៀមរាប សម្តែងនៅប្រាសាទអង្គរវត្ត

(ប្រភព៖ ?)

---

[៣] ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ២០១៨: ១២៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក បើលើកយកប្រវត្តិត្រុដិតាមសម្ដីអ្នកភូមិគោកក្រសាំង(?) ចុះផ្សាយក្នុងឯកសារខាងលើដដែលថា "ត្រុដិមានតាំងពីព្រះអង្គចូលទៅទ្រង់ផ្នួស ព្រះអង្គយកត្រុដិនេះដង្ហែចូលបួស សម្រាប់ជាមគ្គុទេសក៍នាំមុខ ទទួលហែព្រះអង្គទៅដល់ព្រៃកំសាន មានមារតំណែងខ្លួនធ្វើជាប្រើសមកផ្ទាញ់ព្រះអង្គ បានដោះទាំងពីរបាញ់ប្រើសនោះស្លាប់ទៅក៏ក្ដៅក្រហាយដល់ព្រះឥន្ទ្រទេវតា លោកបង្អុរភ្លៀងមក ព្រះអង្គក៏បានទៅបួស"។[៦] ទោះបីយ៉ាងណាក្ដី ក្នុងខ្លឹមសាររៀបរាប់ខាងលើ នាំឱ្យយើងមើលឃើញថាត្រុដិពាក់ព័ន្ធនឹងជំនឿលើធម្មជាតិ សត្វ និងទឹកភ្លៀងសម្រាប់ឆ្នាំខាងមុខ។ មិនតែប៉ុណ្ណោះ ចំពោះការរៀបរាប់ឧបករណ៍សម្ដែង និងគ្រឿងក្មេងក៏ឃើញប្រែប្រួលតាមក្រុម តាមភូមិស្រុកដែរ (រូបលេខ៦)។ ចំណែកឯការភ្ជាប់សាច់រឿងទៅនឹងព្រះសម្មាសមុទ្ធ គឺជារឿងធម្មតាក្នុងព្រេងនិទានខ្មែរ ដែលគេតែងសង្កេតឃើញមកជាហូរហែ។ សូមបញ្ជាក់ថា ចំពោះអ្នកស្រុកសៀមរាប និងតំបន់ខ្លះទៀតតែងលេងត្រុដិម្យ៉ាងទៀតហៅថា "ត្រុដិនាងម៉េវ" ពេលស្រុកភូមិរាំងស្ងួតពុំមានភ្លៀងធ្លាក់។



*រូបលេខ៦ ត្រុដិសម្ដែងនៅតាមប្រាសាទជូនគណអធិបតីទស្សនាកម្សាន្ត (ប្រភព៖?)*

---

[៦] ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ២០១៨: ១៣៣ (សេចក្ដីខាងលើនេះសង្ខេបចេញពីសេចក្ដីដើម)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះទំនុកចម្រៀងរាំត្រុដិ គេសង្កេតឃើញមានសេចក្ដីមិនដូចគ្នាឡើយ ពោលគឺប្រែប្រួលតាមការនិយមនៃវង់ត្រុដិនីមួយៗ ទំនុកខ្លះគេអាចបង្កើតភ្លាមៗតាមហេតុការណ៍ជាក់ស្ដែង។ ប៉ុន្តែជារួមទំនុកច្រៀងទាំងនោះហាក់ដូចជារៀបរាប់ទិដ្ឋភាពក្រុមអ្នករាំត្រុដិដើរដាច់សង្វែងកណ្ដាលថ្ងៃក្ដៅ មានរទេះ មានគោ... ចូលមកសុំរាំមុខផ្ទះអ្នកស្រុក ដើម្បីឱ្យគេដាក់ទានរបស់របរផ្សេងៗ រួចហើយឱ្យពរជ័យគេជាការតបស្នង។ ខាងក្រោមនេះជាទំនុកច្រៀងក្រុមត្រុដិបាត់ដំបងគឺ៖

-ត្រុដិយើងដល់ហើយដល់ដើងរបង រទេះដល់ផងខ្សែរងចង្រ្កង់ ឱណានាងណាខ្សែចងចង្រ្កង់។

-កញ្ជារបងបែក បងហែកហាលថ្ងៃ កញ្ជាចង្រ្រៃបានអ្វីលៅគិន ឱណានាងណាបានអ្វីលៅគិន។

-អាដែងកនយើងឯងមើលអ្វីនុះ ឃើញសសំព្រុស ដូចជាក្រមុំ។ ឱណា...

-ដឹងដៃអ្នករហាល ធ្វើស្រែឥតដាល បានស្រូវបីការុង បើនាងមិនជឿទៅមើលឯក្នុងបានស្រូវបីការុងស៊ីផងលក់ផង។ ឱណា...

-ដៃអ្នកស្រុកភាស ស៊ីតែសម្ងជាស ជុំអាចម៌ចេញខ្លាញ់។ ឱណា...

-ដឹងដៃអ្នកប្រដាក កាត់សក់សាកញ៉ាក ធ្វើដង្ខៅលេងស្រី។ ឱណា...

-រមាំងនាងអើយវារាំងគន្លង វាដេញដល់បងវាកងកន្ទុយ។ ឱណា...

-សន្ទូចបងមួយពង់វង់ត្រឡោក បង្កែលើគោកកន្ទួនភ្ជាត់ក្ទៅ។ ឱណា...

-សន្ទូចបងដាច់ បងលុយទៅចង ក្រពតខាំបងខាំដាច់ខ្នងជើង. ឱណា...

-ផ្ទះធំឈ្មៀងហាប់ ក្រមុំច្រើនកប នៅកៀនជញ្ជាំង។ ឱណា...

-ផ្ទះធំរោងដោល ម្ចាស់គេរត់ចោល ជុំក្លិនស្រាខ្លាំង។ ឱណា...

-អាទង់កន់ឆែត នៅអែបកៀនទឹក យកមកក្នាតផឹក ក្នាតរាំឱ្យមើល។[៩]

---

[៩] សេចក្ដីនេះផ្សាយក្នុងសៀវភៅប្រពៃណីខ្មែរ ដែលប្រមូលចងក្រងដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរ។ សូមអានបន្ថែម "ចម្រៀងត្រុដិនៅភូមិគូ" (ខេត្តឧត្តរមានជ័យ) ដោយ អាន រស្មី ២០២២: ៩៩-១១០។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# *អត្ថបទ៖ ជំនឿរាំត្រុដិក្នុងរដូវចូលឆ្នាំថ្មី*

*បើផ្អែកតាមសេចក្ដីសង្កេតទំនៀមរាំត្រុដិរបស់អ្នកស្រុកក្នុងខេត្តឧត្តរមានជ័យ ដែលជាខេត្តភាគខាងជើងដែរ គេឃើញច្បាស់ថា ខ្លឹមសារចម្រៀងត្រុដិនោះមានចំណុចស្រដៀងគ្នានឹងអ្នកស្រុកបាត់ដំបងដោយអន្ទើៗ។[៦] ចំពោះអត្ថន័យធំនៃការលេងត្រុដិ អ្នកស្រាវជ្រាវយល់ថា លេងក្នុងន័យសុំទឹកភ្លៀង ហើយសូម្បីតែតួអង្គដង្ហែរដើរនាំត្រុដិនោះខ្លះហៅថាមេភ្លៀង ឬមេនាគ។ លើសពីនេះ ការដែលម្ចាស់ផ្ទះជះទឹកដាក់ក្រុមត្រុដិក៏សុទ្ធតែជាការឧបកិច្ចសូមឱ្យភ្លៀងធ្លាក់មកនៅខែពិសាខខាងមុខ។ មិនតែប៉ុណ្ណោះ ចំពោះការបាញ់សម្លាប់ប្រើសដែលជាចំណុចធំបង្អស់នៃល្បែងត្រុដិ គេយល់ថា "និមិត្តរូប" នៃការបញ្ចៀសភាពរាំងស្ងួត។[៧] សូមបញ្ជាក់ដែរថា នៅតាមតំបន់ខ្លះក្រោយសម្ដែងដល់ត្រង់ឈុតបាញ់ប្រើសង៉ាប់ហើយ គេតែងប្រោះទឹកដាក់ប្រើសនោះ ហើយខ្លះថែមទាំង និមន្តព្រះសង្ឃប្រោះទឹកផងក៏មាន (រូបលេខ៥-៦)។ ដោយយល់ពីអត្ថន័យ និងខ្លឹមសារជាទំនៀមដូចរៀបរាប់មកខាងលើ គេសម្គាល់ឃើញក្រសួង មន្ទីរ សាលារៀន និងក្រុមហ៊ុនតូចធំកាន់តែនិយមគាំទ្ររបាំត្រុដិ រាំក្នុងរដូវចូលឆ្នាំថ្មីកាន់តែផុសផុលឡើងពីមួយឆ្នាំទៅមួយឆ្នាំ (រូបលេខ៧-១០)។*



*រូបលេខ៥ ត្រុដិសម្ដែងតាមទំនៀមអ្នកស្រុកសៀមរាប*



*រូបលេខ៦ ព្រះសង្ឃប្រោះព្រំក្រុមរបាំត្រុដិសៀមរាបក្រោយបញ្ចប់ការសម្ដែង*

---

[៦] *អាន រស្មី ២០២២: ៩៩-១១០*

[៧] *អាន រស្មី និង អាំង ជូលាន ២០២២: ២៧-៤០*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*











*របលេខ៧-១០ របាំត្រុដិសម្តែងតាមក្រសួង មន្ទីរ និងក្រុមហ៊ុនតូចធំផ្សេងៗក្នុងរដូវចូលឆ្នាំថ្មី*
*(រូបថត៖ ក្រសួងយុត្តិធម៌, មន្ទីរវប្បធម៌ខេត្តកំពង់ធំ, ផ្សារទំនើប Exchange Square)*

សង្ខេបសេចក្តីមក  របាំត្រុដិដែលអ្នកស្រុកភាគខាងជើងតែងលេងក្នុងរដូវចូលឆ្នាំ គឺមានអត្ថន័យជំពាក់ព័ន្ធនឹងជំនឿលើទឹកភ្លៀងសម្រាប់ឆ្នាំថ្មី។ ចំណែកឯរបាំត្រុដិដែលគេតែងសង្កេតឃើញសម្តែងតាមទីសាធារណៈនានា ហាក់មានលក្ខណៈជាសិល្បៈទស្សនីយភាព សម្តែងក្នុងន័យអបអរសាទរឆ្នាំថ្មី និងក្នុងជំនឿបណ្តេញឧបទ្រពចង្រៃផ្សេងៗ ទន្ទឹមនឹងការបង្ហាញឱ្យឃើញពីការគាំទ្រសិល្បៈប្រពៃណីផងដែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

២០១៨, *ប្រពៃណីខ្មែរ* (ប្រមូលផ្ដុំបោះពុម្ពដោយ EFEO), EFEO, ភ្នំពេញ

ក្រុមជំនុំវចនានុក្រមខ្មែរ

១៩៦៧, *វចនានុក្រមខ្មែរ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌមរតកប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

អាន រស្មី

២០២២, "ចម្រៀងត្រុដិនៅគូមិគូ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៧, ទំ.៩៩-១១០, យសោធរ, ភ្នំពេញ

អាន រស្មី និង អាំង ជូលាន

២០២២, "ត្រុដិ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៧, ទំ. ២៧-៤០, យសោធរ, ភ្នំពេញ

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត